**ព្រះរាជក្រឹត្យ នស/រកត/០៨០០/១៥០**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០០

-យោងតាមសំណូមពរការងារចាំបាច់

**ត្រាស់បង្គាប់**

មាត្រា ១ .- តែងតាំងឯកឧត្តម ញឹក ទណ្ឌារ៉ា ជាឧបការីប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលមានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ .- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅប៉េកាំង ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

**អនុក្រឹត្យ លេខ ៥១ អនក្រ.បក**

**ស្តីពីការផ្តល់**

**និងការប្រើប្រាស់លិខិតឆ្លងដែនការទូត-ផ្លូវការ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីអន្តោប្រវេសន៍

-បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមការចាំបាច់ដើម្បីរៀបចំធ្វើបដិការទិដ្ឋាការដល់លិខិតឆ្លងដែនការទូត និងលិខិតឆ្លងដែនផ្លូវការ ជាមួយបណ្តារដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

-បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០០

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១ .-

អនុក្រឹត្យនេះមានគោលដៅកំណត់ការផ្តល់ និងការប្រើប្រាស់លិខិតឆ្លងដែនការទូត និងផ្លូវការសំរាប់ឥស្សរជន និងមន្ត្រីរាជការ នៃព្រះរាជាណាចក្រកម្ពុជា ដែលសំរាប់ប្រើប្រាស់តែក្នុងពេលបំពេញបេសកកម្មផ្លូវការនៅបរទេសតែប៉ុណ្ណោះ លើកលែងតែព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ឬ សម្តេចព្រះរាជអគ្គមហេសី ។ ចំពោះឥស្សរជន និងមន្ត្រីរាជការដែលធ្វើដំណើរទៅបរទេសក្រៅផ្លូវការត្រូវប្រើប្រាស់លិខិតឆ្លងដែនធម្មតា ។

## ជំពូកទី ២

## អំពីលិខិតឆ្លងដែនការទូត

មាត្រា ២ .-

លិខិតឆ្លងដែនការទូតចេញថ្វាយ និងជូនដល់ឥស្សរជនជាន់ខ្ពស់ខ្មែរទៅតាមលំដាប់ នៃឋានន្តរសក្តិ និងមុខតំណែងដូចខាងក្រោម ព្រមទាំងភរិយា និងកូនដែលនៅក្នុងបន្ទុក នៅលីវ ហើយមានអាយុក្រោម១៨ឆ្នាំ ។

១-ព្រះមហាក្សត្រ-ព្រះមហាក្សត្រិយានី ឬ សម្តេចព្រះរាជអគ្គមហេសី ។

២-ព្រះរាជបុត្រា-ព្រះរាជបុត្រី ព្រមទាំងរាជវង្សានុវង្ស ដែលបញ្ជាក់ដោយក្រសួងព្រះបរមរាជវាំង តាមព្រះរាជតម្រាស់បង្គាប់របស់ព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី ឬសម្ដេចព្រះរាជអគ្គមហេសី។

៣-ប្រធាន និងអនុប្រធានព្រឹទ្ធសភា-ប្រធាន និងអនុប្រធានរដ្ឋសភា - ប្រធាន និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ - ឧត្តមប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រ - នាយករដ្ឋមន្ត្រី - ឧបនាយករដ្ឋមន្ត្រី -ទេសរដ្ឋមន្ត្រី - រដ្ឋមន្ត្រី នៃក្រសួងនានា - អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា - ប្រធានតុលាការកំពូល - អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល - អគ្គលេខាធិការរាជរដ្ឋាភិបាល -អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ និងអគ្គនាយកនគរបាលជាតិ ។

៤-ឥស្សរជនដែលមានងារជាសម្ដេច ។

៥-អតីតប្រធានព្រឹទ្ធសភា - អតីតប្រធានរដ្ឋសភា - អតីតនាយករដ្ឋមន្ត្រី -អតីតរដ្ឋមន្ត្រីក្រសួងការបរទេស ក្រោយពីអនុក្រឹត្យនេះចូលជាធរមាន ។

៦-អ្នកការទូតចាប់ពីអនុព័ន្ធឡើងទៅ ដែលកំពុងបំពេញបេសកកម្មការទូតនៅក្រៅប្រទេស ។

**មាត្រា ៣ .-**

លិខិតឆ្លងដែនការទូតចេញផ្ដល់ និងជូនដល់មន្ត្រីរាជការ និងឥស្សរជនជាន់ខ្ពស់ខ្មែរទៅតាមលំដាប់នៃឋានន្តរសក្ដិ និងមុខតំណែងដូចខាងក្រោម ។ ភរិយា ឬ ស្វាមី ព្រមទាំងកូននៅក្នុងបន្ទុករបស់មន្ត្រីរាជការ និងឥស្សរជនទាំងនោះ ពុំអាចបានលិខិតឆ្លងដែនការទូតកាន់ជាមួយទេ ។

១-សមាជិកព្រឹទ្ធសភា-សមាជិករដ្ឋសភា - ប្រធាន និងអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសមាជិកឧត្ដមក្រុមប្រឹក្សា នៃអង្គចៅក្រម ។

២-រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ នៃក្រសួងស្ថាប័ននានា ។

៣-អគ្គលេខាធិការរងរាជរដ្ឋាភិបាល-អគ្គទេសាភិបាលរងធនាគារជាតិ ។

៤-អនុប្រធានតុលាការកំពូល-អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល-ប្រធានសាលាឧទ្ធរណ៍ -អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

៥-មន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ ចាប់ពីថ្នាក់អគ្គនាយក-អគ្គាធិការឡើងទៅ ដែលមាននៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ។

៦-មន្ត្រីផ្នែកយោធា

ដែលមានឋានៈចាប់ពីប្រធានអគ្គនាយកដ្ឋានចំណុះក្រសួងការពារជាតិឡើងទៅ - អគ្គមេបញ្ជាការរង - នាយសេនាធិការចំរុះ - នាយរងសេនាធិការចំរុះ - មេបញ្ជាការកងទ័ពជើងគោក - មេបញ្ជាការកងទ័ពជើងអាកាស-មេបញ្ជាការកងទ័ពជើងទឹក នៃកងយោធពលខេមរភូមិន្ទ - មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងមន្ត្រីផ្នែកនគរបាល ដែលមានឋានៈជាអគ្គនាយករងនគរបាលជាតិ ។

៧-ទីប្រឹក្សាដែលមានឋានៈស្មើអនុរដ្ឋលេខាធិការឡើងទៅ ។

៨-អតីតឧបនាយករដ្ឋមន្ត្រី ។

៩-ប្រតិភូរាជរដ្ឋាភិបាលដែលទទួលបន្ទុកជាអភិបាល-អភិបាលរងរាជធានីភ្នំពេញ-អភិបាលខេត្ត-ក្រុង ។

១០-ប្រធានពិធីការរបស់ព្រះមហាក្សត្រ - នាយករដ្ឋមន្ត្រី - ព្រឹទ្ធសភា - រដ្ឋសភា - ក្រសួងការបរទេស ។

មាត្រា ៤ .- លិខិតឆ្លងដែនការទូតក៏ចេញប្រគេនសម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងមន្ត្រីសង្ឃដែលមានងារជាសម្តេច ។

មាត្រា ៥ .- សុពលភាព នៃលិខិតឆ្លងដែនការទូត មានរយៈពេលដំបូង បីឆ្នាំ ហើយអាចបន្តសំរាប់រយៈពេលបីឆ្នាំម្តង ក្នុងករណីដែលអ្នកកាន់លិខិត ឆ្លងដែននេះនៅមានមុខងារ និងតួនាទីដូចមានចែងក្នុងមាត្រា ២-៣ និងមាត្រា៤ នៃអនុក្រឹត្យនេះ ។

មន្ត្រីអស់ឋានៈ និងតួនាទី មន្ត្រីចូលនិវត្តន៍ មន្ត្រីដែលមានពិរុទ្ធ ហើយត្រូវបានព្យួរក្របខ័ណ្ឌ និងមន្ត្រីដែលលះបង់រាជការដោយគ្មានមូលហេតុ ចាប់ពីប្រាំមួយខែឡើងទៅ គ្មានសិទ្ធិប្រើប្រាស់លិខិតឆ្លងដែនការទូតទេ ។

## ជំពូកទី ៣

## អំពីលិខិតឆ្លងដែនផ្លូវការ

មាត្រា ៦ .-

លិខិតឆ្លងដែនផ្លូវការចេញផ្តល់ និងជូនដល់មន្ត្រីរាជការស៊ីវិល យោធា និងនគរបាល ព្រមទាំងប្រគេនមន្ត្រីសង្ឃ សំរាប់តែក្នុងករណីដែលត្រូវបំពេញបេសកកម្មផ្លូវការនៅបរទេស ។

មាត្រា ៧ .-

សុពលភាព នៃលិខិតឆ្លងដែនផ្លូវការមានរយៈពេលប្រហាក់ប្រហែលនឹងរយៈពេលបំពេញបេសកកម្មផ្លូវការនៅបរទេស ។

## ជំពូកទី ៤

## សមត្ថកិច្ចផ្តល់ និងដកហូតលិខិតឆ្លងដែន

មាត្រា ៨ .-

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចផ្តល់លិខិតឆ្លងដែនការទូត-ផ្លូវការស្របតាមមាត្រាទាំងឡាយ ដែលមានចែងក្នុងអនុក្រឹត្យនេះ ។

លិខិតឆ្លងដែនការទូត-ផ្លូវការទាំងឡាយណាដែលពុំឆ្លើយតបទៅនឹងមាត្រា២-៣-៤-៥ និងមាត្រា៦ ខាងលើនេះ នឹងលែងមានសុពលភាពប្រើប្រាស់ ចាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០១ តទៅ ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដកហូត ឬបដិសេធ រាល់លិខិតឆ្លងដែនទាំងឡាយណា ដែលអស់សុពលភាព បាត់ ឬ ក្លែងបន្លំ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៩ .-**

ជំពូក ២ ស្តីពីលិខិតឆ្លងដែនការទូត និងជំពូក៣ ស្តីអំពីលិខិតឆ្លងដែនផ្លូវការ នៃអនុក្រឹត្យលេខ ៦៩ អនក្រ.ចុះថ្ងៃទី២៥ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីលិខិតឆ្លងដែន នៃព្រះរាជាណាចក្រកម្ពុជា និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ហត្ថលេខា

ហោ ណាំហុង

★★★

# អនុក្រឹត្យ លេខ ៥២ អនក្រ.បក

## ស្តីពី

## ការផ្ទេរតំណែងអនុវិធាន

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី